# ខែមករា

# គណិតវិទ្យានៅផ្ទះ-ថ្នាក់ទី៥



ពេលអ្នកបញ្ចប់កិច្ចការក្នុងថ្ងៃនិមួយៗសូមគូសរង្វង់ថ្ងៃទី

១. សូមអានឧបករណ៍វាស់ចម្ងាយឡានគ្រួសាររបស់អ្នក។សរសេរចំនួនម៉ៃល៍ជាលេខ។សរសេរចំនួនម៉ៃលជាពាក្យ។

២. ពីផ្ទះរបស់អ្នកទៅសាលារៀនតើមានប៉ុន្មានម៉ៃល,ឬភាគខ្លះរបស់ម៉ៃល?

៣. តើចំនួនម៉ៃលនៅនិងឡានរបស់គ្រួសារអ្នកឥឡូវនេះមានប៉ុន្មានហើយ? បូកនិង១០០។ បូកនិង១,០០០។បូកនិង១០,០០០។

៤. គុណថ្ងៃទីឥឡូវនេះជាមួយនិងថ្ងៃទីដដែល។

៥. រាប់ប្រាំម្តងៗរហូតដល់១៨០។រាប់ថយក្រោយប្រាំម្តងៗពី១៨០ចុះមក។

៦. បូកខ្ទង់ទាំងអស់នូវអាសយដ្ឋានផ្ទះអ្នក។តើផលបូកជាលេខសេសឬគត់។

៧. បូកខ្ទង់ទាំងអស់នូវលេខទូរសព្ទរបស់អ្នកហើយចែកផលបូកនិង៣។

៨. ដើម្បិទៅសាលារៀនតើត្រូវធ្វើប៉ុន្មាននាទី? ដើម្បីមកផ្ទះតើត្រូវធ្វើប៉ុន្មាននាទី?

៩. តើអ្នកត្រូវចំណាយភាគខ្លះនៃថ្ងៃសំរាប់គេង, ធ្វើហុមវ៉ឺក,មើលទូរទស្សន៍អស់ប៉ុន្មាន?

១០. តើអ្នកគេងប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍,មួយខែ,មួយឆ្នាំ?

១១. រាប់មុមកែងនៅលើ:តុ, កៅអី, ធុងសៀវភៅ។

១២. សរសេរឈ្មោះអ្នកជាអក្សរធំ។រាប់មុមកែងនិងមុមស្រួចដែលអ្នកឃើញ។

១៣. ចូរគូរហិចសាហ្គន។ចូរចែកវាជាប្រាំមួយ ។

១៤. ដោះស្រាយ:អាយុអ្នកគុណានិងពាក់កណ្តាលមួយបូកនិងបួន។(អាយុ×១/២)+៤=_____។

១៥. គូរធុងសៀវភៅដែលបើកឡើងដើម្បីអោយវាលាតរាប។

១៦. តើជុំវិញកញ្ចក់ទូរទស្សន៍របស់អ្នកមានប៉ុន្មាន?តើផ្ទៃក្រឡាកញ្ចក់ទូរទស្សន៍អ្នកប៉ុន្មាន?

១៧. គូររូបកំប៉ុងស៊ុបដែលបើកចំហដើម្បីអោយវាលាតសំប៉ែត។

១៨. គូរចតុកោណព្នាយកែងហើយចែកវាជាបីផ្នែក។

១៩. ស្មានពេលដុសធ្មេញរបស់អ្នកមើល។ពេលដុសធ្មេញរបស់អ្នកផ្ទាល់ ។ តើការស្មានរបស់អ្នកប្រហែលគ្នាឬទេ?

២០. ដោះស្រាយ:ផលបូកខ្ទង់ទាំងអស់នៅក្នុងអាសយដ្ឋានរបស់អ្នកគុណានិងពាក់កណ្តាលមួយ។

២១. តើប្រភាគប៉ុន្មានក្នុងមួយម៉ោងដែលអ្នកចំណាយញុំាបាយពេលល្ងាច? តើអ្នកចំណាយញុំាបាយពេលល្ងាចងស់ពេលប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍?

# ខែមករា

# គណិតវិទ្យានៅផ្ទះ-ថ្នាក់ទី៥



២២. ដោះស្រាយ: ១/៣ ពងទាមួយឡ; ២/៣ពងទាមួយឡ;
១/៤ពងទាមួយឡ; ៣/៤ ពងទាមួយឡ។

២៣. ដោះស្រាយ: ១/៦ ពងទាពីរឡ; ២/៦ ពងទាពីរឡ;
៣/៦ ពងទាពីរឡ; ៥/៦ពងទាពីរឡ។

២៤. សរសេរគ្រប់កត្តានៃ ២៤។

២៥. ដោះស្រាយ: ថ្ងៃទីថ្ងៃនេះគុណនិង ៥ ដកអាយុរបស់អ្នក។(ថ្ងៃទី×៥)-អាយុ=______។

២៦. គូរត្រីកោណដែលមានមុមកែង, ត្រីកោណដែលមានមុមស្រួច, និង
ត្រីកោណដែលមានមុមធំជាង៩០និងតូចជាង១៨០ដឺក្រេ។

២៧. តើមានមនុស្សរស់នៅប៉ុន្មាននាក់នៅក្នុងផ្ទះអ្នក?តើអនុបាតរបស់មនុស្សធម្មតា
ហើយនិងមនុស្សសំខាន់មានប៉ុន្មាន?

២៨. តើមនុស្សសំខាន់ដែលជាប់ទាក់ទងនិងគ្រួសារអ្នកមានប៉ុន្មាន?តើអនុបាត
មនុស្សធម្មតាទៅនិងមនុស្សសំខាន់មានប៉ុន្មាន?

២៩. តើអ្នកមើលទូរទស្សន៍ប៉ុន្មានម៉ោងម្សិលមិញ?តើចំនួនភាគរយនៃថ្ងៃដែលអ្នក
ចំណាយពេលមើលទូរទស្សន៍មានប៉ុន្មាន?

៣០. សូមធ្វើប្រក្រតិទិនខែកុម្ភ:។គូសរង្វង់ចំនួនដែលចែកខ្លួនឯងបាននិងលេខមួយ។
**(Prime numbers)**

៣១. តើអនុបាតស្រ:ទៅនិងព្យញ្ជន:មានប៉ុន្មាននៅក្នុងអក្ខរក្រម?